BIBLE
316

# តើព្រះគម្ពីរជាអ្វី?

**តើព្រះគម្ពីរជាអ្វី?** គឺជាព្រះដែលកំពុងមានបន្ទូលមកកាន់អ្នក។ ព្រះគម្ពីរមិនគ្រាន់តែនិយាយអំពីព្រះប៉ុណ្ណោះទេ។ វាលើសពីការបណ្ដាល។ ព្រះគម្ពីរគឺព្រះជាម្ចាស់ជា «ខ្យល់ដង្ហើមរបស់ព្រះ»។ សូមអានព្រះគម្ពីរ។ សូមស្ដាប់ព្រះគម្ពីរ។ ពិចារណាព្រះគម្ពីរ។ រៀនពីព្រះគម្ពីរ។ អនុវត្តនៅក្នុងជីវិតរបស់អ្នក។ លោកសាវកពេត្រុសបានសរសេរថា *«នោះត្រូវឲ្យសង្វាតរកទឹកដោះសុទ្ធ ខាងឯព្រលឹងវិញ្ញាណវិញ ដូចជាទារកដែលទើបនឹងកើត ដើម្បីឲ្យអ្នករាល់គ្នាបានចំរើនធំឡើង ដរាបដល់បានសង្គ្រោះ»* ១ ពេត្រុស ២:២។

**តើអ្វីទៅដែលធ្វើឱ្យព្រះគម្ពីររកអ្វីមកប្រៀបផ្ទឹមបាន?** ព្រះគម្ពីរមាន៦៦កណ្ឌ ត្រូវបានសរសេរឡើងជាបីភាសា (ហេព្រើរ អារ៉ាមេក និងក្រិក) តាមរយៈមនុស្សសែបសិបនាក់ ចំណាយពេលប្រហែល ១៦០០ឆ្នាំ ជាមួយនឹងរឿងរ៉ាវតែមួយ ហើយប្រធានបទស្របគ្នា សរសេរឆ្លងកាត់ពេលវេលារាប់សតវត្សរ៍។ គម្ពីរសញ្ញាថ្មីត្រូវបានផ្ទៀងផ្ទាត់ភាពច្បាស់លាស់ និងពិតប្រាកដជាមួយអត្ថបទបុរាណដើមពេញ ឬជាផ្នែកៗជាង៥០០០ឯកសារ។ សុក្រិត្យភាពរបស់ព្រះគម្ពីរត្រូវបានបញ្ជាក់ដោយព្រះគម្ពីរខ្លួនឯង។ ទំនាយផ្សេងៗបានសម្រេច តាមរយៈការរកឃើញរបស់បុរាណវិទ្យាសម័យទំនើប នៅក្នុងភូមិសាស្ត្រជាក់លាក់ និងនៅក្នុងប្រាជ្ញានៃសុភាសិតដែលគ្មានដែនកំណត់។ ព្រះគម្ពីរសំខាន់បំផុត និងជាសៀវភៅដែលមានឥទ្ធិពលបំផុតដែលបានសរសេរឡើង។ គ្មានសៀវភៅណាបានបោះពុម្ពផ្សាយច្រើន និងចែកចាយយ៉ាងទូលំទូលាយ និងបកប្រែច្រើនភាសា បំផ្លាស់បំប្រែជីវិត និងមាននៅជាច្រើនសតវត្សរ៍ដូចព្រះគម្ពីរទេ។ ព្រះគម្ពីរគឺជាសិទ្ធិអំណាចចុងក្រោយដែលយើងត្រូវជឿ និងសម្រាប់ជារបៀបដែលយើងត្រូវរស់នៅតាម។ ព្រះគម្ពីរឈរខ្ពស់លើសជាងសៀវភៅណាៗទាំងអស់។

**តើអ្វីទៅជាចរិតលក្ខណៈរបស់ព្រះគម្ពីរ?**

ព្រះគម្ពីរគឺជាព្រះវិញ្ញាណណែព្រះ *«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែង»* ២ ធីម៉ូថេ ៣:១៦។

ព្រះគម្ពីរគឺជាសេចក្តីពិត។ ព្រះយេស៊ូវបានអធិស្ឋាន *«សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិត គឺជាព្រះបន្ទូលរបស់ទ្រង់»* យ៉ូហាន ១៧:១៧។

ព្រះគម្ពីរច្បាស់លាស់ចំពោះព័ត៌មានលម្អិត។ ព្រះយេស៊ូវមានបន្ទូលថា *«ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើ១ ឬក្បៀស១នៅក្នុងក្រិត្យវិន័យ ត្រូវបាត់ឡើយ ដរាបដល់កាលណាមេឃ នឹងផែនដី បានកន្លងបាត់ទៅ គឺទាល់តែសេចក្តីទាំងអស់បានសំរេច ដោយសព្វគ្រប់»* ម៉ាថាយ ៥:១៨។ ជាអត្ថបទដើមដែលបានរក្សានូវសុក្រឹត្យភាព ជាការបកប្រែដែលច្បាស់លាស់ល្អបំផុតពីពាក្យមួយទៅពាក្យមួយលើសជាង៩៩%។

ព្រះគម្ពីរសុទ្ធស្អាត។ *«ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះសុទ្ធស្អាតទាំងអស់គឺដូចប្រាក់ដែលគេសាកក្នុងបាវធ្វើពីដីហើយបានសំរងអស់៧ដងផង»* ទំនុកតម្កើង ១២:៦។

ព្រះគម្ពីរអស់កល្ប។ *«ស្មៅក៏ស្វិតក្រៀម ហើយផ្កាពោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប»* អេសាយ ៤០:៨។ ព្រះគម្ពីរមានប្រសិទ្ធភាពក្នុងពេលសព្វថ្ងៃនេះ ដូចពេលដែលព្រះគម្ពីរសរសេរដំបូងដែរ។

ព្រះគម្ពីរពេញដោយអំណាច។ ហេព្រើរ ៤:១២ *«ពីព្រោះ ឯព្រះបន្ទូលនៃព្រះនោះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខ២ ទាំងធ្លុះចូលទៅ ទាល់តែកាត់ព្រលឹងនឹងវិញ្ញាណ ហើយសន្លាក់ នឹងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលចិត្តគិត ហើយដែលសំរេចដែរ»*។

**តើមានអត្ថប្រយោជន៍អ្វីខ្លះសម្រាប់ខ្លួនឯងចេញពីព្រះគម្ពីរ?**

ព្រះគម្ពីរប្រដាប់យើង។ *«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ»* ២ ធីម៉ូថេ ៣:១៦-១៧។

ព្រះគម្ពីរជួយយើងមិនឱ្យធ្វើបាប។ ទំនុកតម្កើង១១៩:៩, ១១ ប្រាប់យើងពីរបៀបធ្វើឱ្យការនោះកើតឡើង *«៩មនុស្សកំឡោះនឹងសំអាតផ្លូវដែលខ្លួនប្រព្រឹត្តដោយសារអ្វីគឺដោយប្រយ័តនឹងប្រព្រឹត្តតាមព្រះបន្ទូលនៃទ្រង់* ហើយ *«១១ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្តប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ»*។

ព្រះគម្ពីរផ្តល់ការណែនាំសម្រាប់យើងនៅថ្ងៃនេះ (ជំហានបន្ទាប់របស់យើង) និងការតម្រង់ផ្លូវសម្រាប់អនាគតរបស់យើង (ផ្លូវដើម្បីដើរតាម) *«ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង»* ទំនុកតម្កើង ១១៩:១០៥។

ព្រះគម្ពីរផ្តល់ប្រាជ្ញា។ «*ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញក៏ធ្វើឲ្យមនុស្សឆោតល្ងង់មានយោបល់*» ទំនុកតម្កើង ១១៩:១៣០។ ប្រាជ្ញាដែលមានពេលវេលាកំណត់គឺរកឃើញនៅក្នុងសុភាសិតក្នុងគម្ពីរសញ្ញាចាស់។

ព្រះគម្ពីរជួយយើងឆ្លងកាត់ទុក្ខលំបាក។ ទំនុកតម្កើង ១១៩:៥០ លើកទឹកចិត្តយើង «*នេះហើយជាសេចក្តីកំសាន្តចិត្តដល់ទូលបង្គំ ក្នុងវេលាដែលទូលបង្គំកើតទុក្ខព្រួយគឺព្រះបន្ទូលទ្រង់បានប្រោស ឲ្យទូលបង្គំមានកំឡាំងឡើង*»។

ព្រះគម្ពីរផ្តល់សេចក្តីសង្ឃឹម។ «*ដ្បិតអស់ទាំងសេចក្តីដែលបានចែងទុកមកជាមុន នោះបានចែងសំរាប់នឹងបង្រៀនដល់យើងរាល់គ្នា ដើម្បីឲ្យយើងបានសេចក្តីសង្ឃឹម ដោយសេចក្តីអត់ធន់ នឹងសេចក្តីកំសាន្តចិត្ត ដោយសារគម្ពីរ*» រ៉ូម ១៥:៤។

ព្រះគម្ពីរផ្តល់សេចក្តីសុខសាន្ត។ ទំនុកតម្កើង ១១៩:១៦៥ សន្យាថា «*ពួកអ្នកដែលស្រឡាញ់ក្រិត្យវិន័យទ្រង់ នោះមានសេចក្តីសុខដ៏លើសលប់ ហើយគ្មានហេតុនឹងចំពប់ដួលឡើយ*»។

ព្រះគម្ពីរនាំមកនូវអំណរ។ យេរេមា ១៥:១៦ ផ្តល់ឧទាហរណ៍ «*ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្តីអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ ដ្បិតឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ ទូលបង្គំបានហៅតាមព្រះនាមទ្រង់*»។

**តើអ្នកគួរអាន ឬស្តាប់ព្រះគម្ពីរយ៉ាងដូចម្តេច?** ពិនិត្យលើសពីមួយខ។ ពិចារណាគោលបំណងបួននៃ «*គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅជំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត*» ២ ធីម៉ូថេ ៣:១៦។ ពេលអ្នកអាន ឬស្តាប់ សូមសួរបួនសំណួរនេះ។ តើការនេះបង្រៀនអ្វីដល់ខ្ញុំ? តើការនេះដាស់តឿនខ្ញុំអំពីអ្វី? តើខ្ញុំគួរកែប្រែអ្វីខ្លះ? តើការនេះបង្រៀនខ្ញុំឱ្យកាន់តែសុចរិតឡើងយ៉ាងដូចម្តេច?

**ចុះបើ ខ្ញុំអត់មានព្រះគម្ពីរ?** ត្រូវខំប្រឹងឱ្យអស់ពីលទ្ធភាពដើម្បីទិញព្រះគម្ពីរមួយដែលមានការបកប្រែល្អ។ ប្រសិនបើ អ្នកមិនមានលទ្ធភាពទិញទេ មានព្រះគម្ពីរដែលឥតបង់ថ្លៃជាច្រើនអាចអាន និងស្តាប់នៅតាមអនឡាញ។ ពិចារណាជាមួយមិត្តភក្តិម្នាក់ ឬច្រើននាក់ ហើយចែករំលែកគ្នា។ ឬ សួរពួកជំនុំរបស់អ្នក ឬបងប្អូនរួមជំនឿ ដើម្បីឱ្យនរណាម្នាក់អានគម្ពីរដល់ក្រុម ហើយស្តាប់យ៉ាងយកចិត្តទុកដាក់។ «*តែទ្រង់មានបន្ទូលតបថា ស៊ូថាដូច្នេះវិញ មានពរហើយ អស់អ្នកដែលស្តាប់ព្រះបន្ទូល ហើយកាន់តាម*» លូកា ១១:២៨។

**តើមានខគម្ពីរពិសេសអ្វីខ្លះ សម្រាប់គ្រូបង្រៀនព្រះគម្ពីរ និងអ្នកដឹកនាំ?** ធ្វើជាសិស្សរបស់ព្រះយេស៊ូវ នៅជាប់ (រស់នៅ) ក្នុងព្រះបន្ទូល។ «*នោះព្រះយេស៊ូវមានបន្ទូល ទៅពួកសាសន៍យូដាដែលជឿដល់ទ្រង់ថា បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន*» យ៉ូហាន ៨:៣១។ សិក្សាព្រះគម្ពីរដែលមានការទទួលស្គាល់។ «*ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ*» ២ ធីម៉ូថេ ២:១៥។

**ហេតុអ្វីបានជាព្រះគម្ពីរសំខាន់ជាដរាប?** លោកសាវកយ៉ូហានបានពន្យល់ *ព្រះយេស៊ូវក៏ធ្វើទីសំគាល់ជាច្រើនទៀត នៅមុខពួកសិស្សទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ បានចែងទុកតែប៉ុណ្ណេះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ*» យ៉ូហាន ២០:៣០-៣១។ តើអ្នកជឿលើព្រះយេស៊ូវ និងមានជីវិតអស់កល្បជានិច្ចយ៉ាងដូចម្តេច? សូមស្វែងរកពីរបៀបនៅ www.Gospel316.org។

**«ស្មៅក៏ស្វិតក្រៀម ហើយផ្កាពោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប» អេសាយ ៤០:៨។**

---

*តើព្រះគម្ពីរជាអ្វី?* © ២០២៥ ដោយលោក ចន ឌី. ម៉ូរីស III ( John D. Morris III) បោះពុម្ពផ្សាយដោយ កិច្ចការមួយប្រាំបី។ អ្នកអាចបោះពុម្ព ថតចម្លង ផុស អ៊ីម៉ែល ឬផ្ញើសារជាមួយនឹងមាតិកាដើម ដោយមិនមានការកែប្រែ ជាមួយសេចក្តីថ្លែងទាំងស្រុងដោយឥតបង់ថ្លៃ។ អ្នកអាចដាក់បន្ថែមព័ន្ធកិច្ច ឬឈ្មោះក្រុមជំនុំ ឬនិមិត្តសញ្ញាតំណាងរបស់អ្នកនៅខាងលើនៃទំព័រទីមួយខាងលើ ហើយបន្ថែមព័ត៌មានទំនាក់ទំនងខាងក្រោមបន្ទាត់ខាងក្រោមនៅទំព័រទីពីរ។ Bible316 ត្រូវបានផ្អែកលើព្រះគម្ពីរតែមួយគត់ ត្រូវបានបង្កើតឡើងដើម្បីជួយឱ្យមនុស្សបានជឿលើព្រះយេស៊ូវគ្រីស្ទ ហើយបន្ទាប់មកលូតលាស់ទៅជាសិស្សរបស់ព្រះអង្គ។ អ្នកអាចអ៊ីម៉ែលមកកាន់កិច្ចការមួយប្រាំបី (ជាភាសាអង់គ្លេសបើអាច) Hello@Mail316.org. សេវាបកប្រែខុសពីភាសាអង់គ្លេសត្រូវបានផ្តល់ជូនដោយ www.ChristianLingua.com. តើព្រះគម្ពីរជាអ្វី? មាន៩៨ភាសា ដោយឥតគិតថ្លៃនៅ www.Bible316.org. ការដកស្រង់ព្រះគម្ពីរជាភាសាអង់គ្លេសគឺដកស្រង់មកពី The Lockman Foundation's New American Standard Bible ១៩៩៥. ហើយព្រះគម្ពីរដែលដកស្រង់នៅក្នុងការបកប្រែនេះគឺចេញពីគម្ពីរ ពគប។